1918년, 근대 역사에서 가장 치명적인 질병이 발발하여 전 세계를 휩쓸었습니다.
그 병은 유행성 독감이었는데, 이것은 그냥 평범한 독감이 아니었습니다.…

무서운 독감

여기에는 또한 현재 전 세계를 위협하는 질병에 어떻게 대처할 수 있을 것인가 하는 **문제가** 있습니다.

NO ORDINARY FLU
ម៉ែ!
អ្នកណាហ្នឹង?
FAMILY PHOTOS
គាត់គឺជារឹំទួតរបស់កូន
ឈ្មោះ អតធ្មើ។
គាត់បានស្លាប់
ដោយសារជម្ងឺអាសន្នរោគ
ក្រូនផ្តាសាយធំអេស្ប៉ាញ។
ម៉ែឮគេនិយាយថា ការស្លាប់របស់គាត់
បានធ្វើឲ្យលោកយាយទួត ម៉ារ
របស់កូនឈឺចិត្តស្ទើរបាត់បង់ជីវិត។
ប៉ុន្តែគាត់ដូចជានៅក្មេងណាស់!
រឿងរ៉ាវបានកើតឡើងយ៉ាងមេចខ្លះម៉ែ?

ទោរផ្លូវស្ទឹកឈើគ្រុះ ក្នុងឆ្នាំ 1918 សង្រ្គាមលោកលើកទីមួយកំពុងវិលទោរកភាពស្ងប់រម្ងាប់បន្តិចម្តង។...





តែពីរបីអាទិត្យប៉ុណ្ណោះ, ជម្ងឺឆ្លងក្រុនផ្តាសាយធំបានរាលដាលមកដល់, យាយទួតរបស់ភូនគឺជាមនុស្សមុនគេបង្អស់ ដែលបានធ្លាក់ខ្លួនឈឺ។
វាឈឺរវើរវាយខ្លាំងណាស់។ ម៉ែត្រូវនៅមើលថែជម្ងឺវា។ អតធើរ៉ូ, ភូនឯងត្រូវទៅជួយលក់ឥវ៉ាន់ជំនួសម៉ែនៅផ្សារ។
តែមួយពាក្រិចភ្នែកសោះ, ជីវិតរបស់ពួកគេបានក្រឡាប់ចាក់ទាំងស្រុង។
LINCOLN THEATER
CLOSED
INFLUENZA
គ្មានការចែកចាយឥវ៉ាន់ទៀថ្ងៃនេះ។ ម៉ែក្សឈឺធ្ងន់ណាស់។
SPECIAL
BUY U.S BONDS
ពេលម្តាយរបស់គាត់បានធ្លាក់ខ្លួនឈឺ, អ៊ីទួត អតធើរ៉ូ គឺជាអ្នកមើលថែទាំជម្ងឺរបស់គាត់ និងជម្ងឺលោកយាយទួត មា៉ារា។
អតធើរ៉ូ, យើងមិនមានគិលានុបដ្ឋាយិកាណានៅទំនេរទេ។ ត្រូពេទ្យ និងគិលានុបដ្ឋាយិការបស់យើងច្រើនណាស់កំពុងធ្លាក់ខ្លួនឈឺ, ដូចអ្នកឃើញស្រាប់ហើយ, មនុស្សឈឺពេញស្រុក។
ហាងលក់ទំនិញក៏មិនមានសតាពល្លប៉ន្មានដែរ។
ខ្ញុំសុំទោសអ្នកស្រី។ គ្មានអ្នកណាអាចដឹកជញ្ជូនឥវ៉ាន់មកឲ្យ យើងបានទេ។

ទីក្រុងទាំងមូលបានទទួលរងវិបត្តិជម្ងឺឆ្លងនេះ។
GOING OUT OF BUSINESS
កម្មវិធី
ថ្វាយបង្គំព្រះ
ត្រូវអាក់ខាន
សំណាងល្អ, ពីរបីអាទិត្យក្រោយមក, លោកយាយទួត ម៉ារា ហើយនិងម្តាយរបស់គាត់បានជា
ក្រាន់បើឡើងវិញ។
ប៉ុន្តែគ្រួសារទាំងមូលមិនទាន់ឆ្លងផុតពីគ្រោះថ្នាក់នៅឡើយទេ។
ឃ្ញស!
ឃ្ញស!
អ៊ំទួត អតធ្មើរ
បានធ្លាក់ខ្លួនឈឺ
ជាទម្ងន់។
DAILY NEWS
ឃ្ញស!
ឃ្ញស!
ឃ្ញស!

ដូចពួកយុវជនកំឡោះៗឯទៀតដែរ, អ៊ិទួត អតធើរ៉ូ របស់កូនបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង, យ៉ាងទាន់ហន់។
គាត់ស្លាប់លាចាកលោកនេះទៅទាំងតក់ក្រហល់។
គាត់បានស្លាប់
នៅអេលាស្លែកឡើង
ត្រប់គ្នាខ្លោចផ្សាចិត្តណាស់។
ខ្ញុំសុំទោសអ្នកស្រី។ យើងអស់ក្តារមឈូសដាក់សពហើយ។
យើងមិនអាចធ្វើបុណ្យសព ឬធ្វើពិធីជួបជុំគ្នាអ្វីបានទេ ពីព្រោះជម្ងឺគ្រុនផ្តាសាយធំនេះអាចឆ្លងរាលដាលដល់មនុស្សផ្សេងៗទៀតណា។
យាយទួត ម៉ារ៉ា របស់កូនឈឺចិត្តជាងអ្នកណាៗទាំងអស់។
មនុស្សច្រើនណាស់បានស្លាប់។ 50 លាននាក់បានស្លាប់ដោយសារជម្ងឺឆ្លងទូទាំងពិភពលោកនេះ, 675,000 នាក់បានស្លាប់នៅក្នុងសហរដ្ឋអាមេរិក។
គិតទៅ អន្តរាយជីវិតមនុស្សអស់សន្ធឹកណាស់, តែក៏មានមនុស្សម្នាច្រើនណាស់ដែរបានរស់រួចជីវិតពីអាសន្នរោគមហាប្រល័យនេះ។
យាយទួត ម៉ារ៉ា របស់កូនគឺជាមនុស្សដ៏កម្រម្នាក់ដែលបានរស់រួចជីវិតពីមហាវិនាសកម្មនោះឯង។


"យើងទាំងអស់គ្នាគឺជាកូនចៅរបស់បណ្តាមនុស្ស ដែលបានរស់រួចជីវិតពីជម្ងឺឆ្លងពេញពិភពលោកនៃឆ្នាំ 1918 នោះហើយ។"
ប៉ុន្តែជម្ងឺឆ្លងគ្រុនផ្តាសាយធំពេញពិភពលោកនោះ បានកន្លងផុតទៅហើយ។
ក្រោយមកទៀត៖
"...ពួកអ្នកឯកទេសខាងផ្នែកសុខភាពកំពុងព្រួយបារម្ភថា មេរោគវីរុសគ្រុនផ្តាសាយធំថ្មីអាចបង្កការឆ្លងរាលដាលពេញពិភពលោកម្តងទៀត..."
ម៉ែ...!
FLU
ជម្ងឺគ្រុនផ្តាសាយធំឆ្លងរាលដាលពេញពិភពលោកមានលក្ខណៈខុសប្លែកពីជម្ងឺគ្រុនផ្តាសាយធំ ដែលយើងធាប់ឃើញកើតមានទៅរៀងរាល់រដូវរងា។
FLU
វាគឺជាជម្ងឺមួយប្រភេទ ដែលបង្កឡើងដោយមេរោគវីរុសថ្មីមួយ ដែលរាងកាយរបស់មនុស្សយើងមិនធ្លាប់ជួបប្រទះទាល់តែសោះ។
FLU

រាងកាយរបស់យើងនឹងមានបញ្ហាក្នុងការប្រយុទ្ធទប់ទល់ជាមួយនឹងមេរោគ
គ្រុនផ្តាសាយធំថ្មីមួយនេះ។



នេះគឺជាមេរោគវីរុស
គ្រុនផ្តាសាយធំ ដែល
បានពង្រីកឲ្យឃើញធំ
រាប់ពាន់ដង។

ខុសពីជម្ងឺគ្រុនផ្តាសាយធំដែលយើងឃើញរ្យុងរាល់រដូវរងា, គ្មានទណាទាន់
រកឃើញថ្នាំបង្ការរោគគ្រុនផ្តាសាយធំឆ្លងពេញពិភពលោកនេះទៅឡើយទេ។

មេរោគវីរុសឆ្លងរាលដាលពេញពិភពលោកនេះនឹងឆ្លងរាតត្បាតយ៉ាងឆាប់រហ័សតាមរយៈការប៉ះពាល់គ្នារវាងមនុស្សនិងមនុស្ស។



ជម្ងឺគ្រុនផ្តាសាធំឆ្លងរាលដាលពេញពិភពលោកនេះនឹងឆ្លងរាតត្បាត
ទៅគ្រប់ច្រកល្ហកនៃពិភពលោក។ ជីវិតមនុស្សសត្វនឹងត្រូវក្រឡាប់ចាក់
ទៅគ្រប់ទីកន្លែង, រ្យុងរាល់ថ្ងៃ។



ដើម្បីជួយកាត់បន្ថយល្បឿនរាតត្បាតនៃជម្ងឺ, សាលារ្យុន, និងមន្ទីរ
ថែទាំក្មេងទារអាចនឹងត្រូវបិទទ្វារមួយគ្រាសិន។

មនុស្សម្នាទឹងមិនអាចចេញទៅរកស៊ីធ្វើការងារអ៊ីចានទេ។
CLOSED
កិច្ចការសាធារណៈនានាក៏អាចទឹងត្រូវបិទផ្អាក ជាបណ្តោះអាសន្ន។
ក្នុងស្ថានភាពបែបនេះ, វាអាចទឹងបង្កឲ្យមានការពិបាក ដល់ការស្វែងរកថ្នាំពេទ្យមកព្យាបាលជម្ងឺ។
EMERGENCY
លោកវេជ្ជបណ្ឌិត វែន ក៏ឈឺដែរ។ ខ្ញុំមិនដឹងថា យើងគួរធ្វើយ៉ាងណាទេ។
ប៉ុន្តែគេអាចព្យាបាលអ្នកជម្ងឺត្រូនផ្តាសាយធំភាគច្រើននៅទឹងផ្ទះបាន។
វាអាចមិនដូនជាបដូចឆ្នាំ 1918 ពេកទេ។ ជម្ងឺត្រូនផ្តាសាយធំឆ្លងពេញពិភពលោកពីរឆ្នាប់កើតឡើងក្រោយមកទៀតដែរ, ម្តងនៅឆ្នាំ 1957 ម្តងទៀតនៅឆ្នាំ 1968។
1957
1968
តែទោះជាវាមិនទាន់ធ្ងន់ធ្ងរណាស់ណាក៏ដោយ, ក៏យើងត្រូវតែត្រៀមជើងការទុកជាមុន។

ត្រូវស្នាក់នៅតែក្នុងផ្ទះយ៉ាងហោចណាស់ក៏មួយ អាទិត្យដែរ *។

* ជាចំនួនជិតិចបំផុត, ព្រោះថា ការរាតត្បាតពេញពិភពលោកនេះអាចស្ថិតនៅជាការគំរាមកំហែងដល់ជីវិតរហូតរាប់អាទិត្យ ឬអាចរាប់ខែផងក៏មាន។

ចូរស្តុកទុកគ្រឿងជ.ត់ជ.ង់សុខភាព និងថ្នាំពេទ្យឲ្យបានច្រើន។

ចូររើសរកមនុស្សទុកឲ្យជួយមើលក្មេង ពេលណាសាលារៀនត្រូវបិទទ្វារ។

បើសិនជាអាច, ចូររៀបចំផែនការយ៉ាងណា ឲ្យអ្នកអាចធ្វើការពីផ្ទះ ដោយមិនចាំបាច់ទៅធ្វើនឹងកន្លែងផ្តាល់។

ចូរត្រៀមខ្លួនចាំជួយមនុស្សជិតខាងជង ពេលណាការឆ្លងរាតត្បាតពេញពិភពលោកមកដល់។

ចូរទប់ស្កាត់មេរោគក្រូនផ្តាសាយធំ។ មេរោគនេះអាចឆ្លងរាលដាល ពេលណាមនុស្សក្អក ឬកណ្តាស។

ឬពេលណាដៃប្រឡាក់មេរោគគ្រុនផ្តាសាធំប៉ះអ្វីមួយ...
ឃ្លស់
...នោះពពួកមេរោគនឹងចម្លងខ្លួនទៅទំលើវត្ថុទាំងនោះ។
មេរោគគ្រុនផ្តាសាយធំអាចរស់នៅលើវត្ថុទាំងនោះបានរាប់ថ្ងៃ។
ការលាងដៃឲ្យបានញឹកញាប់គឺជាវិធីការពារមេរោគឆ្លងដ៏មានប្រសិទ្ធភាព។
SOAP
ចូរប្រើប្រដាប់ជូតសម្ភាតដៃដែលមានជាតិអាកុលប្រសិនបើអ្នកគ្មានសាប៊ូ និងទឹកនៅក្បែរខ្លួនទេនោះ។
HAND SANITIZER
60% ALCOHOL
ចូរទប់ស្កាត់មេរោគគ្រុនផ្តាសាយធំដោយខ្ទប់មាត់ឬច្រមុះរបស់អ្នក ពេលណាអ្នកក្អក ឬកណ្តាស។
A-A-
CHOO!
A-CHOO!
A-CHOO!
ចូរខំស្វែងយល់អំពីជម្ងឺគ្រុនផ្តាសាយធំឆ្លងរាលដាលពេញពិភពលោកពីក្រសួងសុខាភិបាលរបស់អ្នក ឬពីទំព័រីបសៃត៍នេះ។
www.pandemicflu.gov
PandemicFlu
ឃ្លក ឃ្លក
គ្មានន័យណាដឹងអំពីពេលវេលាដែលជម្ងឺឆ្លងរាលដាលពេញពិភពលោកនេះ មកដល់ទេ, មែនទេម៉ែ?
មែនហើយកូន។ ប៉ុន្តែបើយើងត្រៀមខ្លួនជាមុន, យើងអាចទប់ទល់នឹងការឆ្លងរាលដាលពេញពិភពលោកនេះ បានដោយងាយស្រួលពេលណាវារាលមកដល់ណា។
ហើយមនុស្សភាគច្រើននឹងបានរស់រួចជីវិតពីការឆ្លងរាលដាលពេញពិភពលោក បើទោះជាជម្ងឺនោះកាចសាហាវខ្លាំងប៉ុណ្ណាក៏ដោយ, ដូចលោកយាយទួត ម៉ារា របស់កូនអញ្ចឹង។

សទ្ទានុក្រម ៖

Influenza (or flu) – គ្រុនផ្តាសាយធំ ៖ ជម្ងឺម្យ៉ាងដែលមានមេរោគនៃជម្ងឺគ្រុនផ្តាសាយធំឆ្លងរាតត្បាតស្ទើរងក្នុងរន្ធច្រមុះ, បំពង់ក, និងស្លត។ គ្រុនផ្តាសាយធំអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់។

Pandemic – ការឆ្លងរាលដាលពេញពិភពលោក ៖ ជម្ងឺម្យ៉ាងដែលចាប់ផ្តើមនៅត្រង់ទីកន្លែងមួយ រួចឆ្លងរាលដាលរាតត្បាតជុំវិញពិភពលោក។

Virus – មេរោគឆ្លង, វីរុស, មេរោគវីរុស ៖ មេរោគម្យ៉ាងដែលអាចបណ្តាលឲ្យមានជម្ងឺកាចល្មម, ដូចជាជម្ងឺគ្រុនរងាធម្មតា, ឬជម្ងឺខ្លាំងក្លាខ្លះ។ ទៀត។ ថ្នាំអង់ទីប៊ីយោទិកមិនអាចសម្លាប់ពពួកមេរោគឆ្លងប្រភេទវីរុសបានទេ។

ការទទួលស្គាល់

រៀបរៀងដោយ Public Health – Seattle & King County Advanced Practice Center

គំនិតអត្ថបទ និងសាច់រឿងដោយ Meredith Li-Vollmer និង Matthew French

វិចិត្ររូបភាពដោយ David Lasky

ឧបត្ថម្ភមូលនិធិដោយ Cooperative Agreement Number U50/CCU302718 ពីមជ្ឈមណ្ឌល Centers for Disease Control and Prevention (CDC) រហូតដល់សព្វមុខមន្ត្រីនៃ National Association of County & City Health Officials (NACCHO)។ ខ្លឹមសារក្នុងសាច់រឿងនេះគឺជាស្នាដៃ និងការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ហើយមិនប្រាកដជាឆ្លុះបញ្ចាំនូវទស្សនៈផ្លូវការរបស់ CDC ឬ NACCHO ឡើយ។

NACCHO
National Association of County & City Health Officials
The National Connection for Local Public Health

APC
Advanced Practice Centers

Public Health
Seattle & King County